ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គិសនីកម្ពុជា

លេខៈ ៣៥៥៣ អកៈរប

**សូមគោរពជូន**

**ឯកឧត្តម ជា សុផារ៉ា**

**ទេសរដ្ឋមន្ត្រី និងជា រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

***ឯកឧត្តម ទេសរដ្ឋមន្ត្រី និងជា រដ្ឋមន្ត្រី ជាទីគោរព ដ៏ខ្ពង់ខ្ពស់ !***

តាងនាមឲ្យថ្នាក់ដឹកនាំ និយោជិត-កម្មករអគ្គិសនីកម្ពុជាទាំងអស់ និងក្នុងនាមរូបខ្ញុំបាទផ្ទាល់ ខ្ញុំបាទ សូមសម្តែងនូវការចូលរួមអបអរសាទរគាំទ្រយ៉ាងពេញទំហឹងជាទីបំផុត និងប្រកបទៅដោយមនោសញ្ចេតនារំភើបរីករាយយ៉ាងក្រៃលែងនៅក្នុងឱកាសដែល ឯកឧត្តម ត្រូវបានតែងតាំង ជា **ទេសរដ្ឋមន្ត្រី និងជា រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់** តាម ព្រះរាជក្រឹត្យនស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ពិតជា ស័ក្តិសមជាទីបំផុត ចំពោះស្នាដៃដ៏ឧត្តុង្គឧត្តមរបស់ ឯកឧត្តម កន្លងមក ដែលបានខិតខំបញ្ចេញយកអស់នូវកម្លាំងកាយ ចិត្ត ប្រាជ្ញា ស្មារតី ពុះពារគ្រប់ឧបសគ្គ ដើម្បីបម្រើផលប្រយោជន៍ ជាតិ សាសនា ព្រះមហាក្សត្រ ។

ជាថ្មីម្តងទៀត តាងនាមឲ្យថ្នាក់ដឹកនាំ និយោជិត-កម្មករអគ្គិសនីកម្ពុជាទាំងអស់ និងក្នុងនាមរូបខ្ញុំបាទផ្ទាល់ ខ្ញុំបាទ សូមប្រសិទ្ធពរជ័យ បវរសួស្តី សិរីមង្គល វិបុលសុខគ្រប់ប្រការ ជូនចំពោះ ឯកឧត្តម ព្រមទាំង ក្រុមគ្រួសារ ជាទីស្រឡាញ់ទាំងអស់ នៅក្នុងឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរឆ្នាំវក អដ្ឋស័ក ព.ស ២៥៦០ គ.ស ២០១៦ សូមទទួលបាននូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

សូម ឯកឧត្តម ទេសរដ្ឋមន្ត្រី និងជា រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មេត្តាទទួលនូវសេចក្តីគោរព ដ៏ ខ្ពង់ខ្ពស់ អំពីខ្ញុំបាទ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែមេសា ឆ្នាំ២០១៦

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា**

**ទទួលបន្ទុកជា អគ្គនាយកអគ្គិសនីកម្ពុជា**

ELECTRICITE DU CAMBODGE

**កែវ_រតនៈ**